# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៧...សសរ

## សេចក្តីសម្រេច

ស្តីពី

ការកែសម្រួល

សមាសភាពគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសម្រេចលេខ ០៣ សសរ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ស ម្រេ ច

**ប្រការ ១ :** សមាសភាពនៃគណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ ដែលមានចែងក្នុងប្រការ ១ នៃសេចក្តីសម្រេចលេខ០៣ សសរ ចុះថ្ងៃ១៥ ខែមករា ឆ្នាំ ២០០១ ត្រូវបានកែសម្រួល ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ស៊ុន ចាន់ថុល | រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម | ឯម សំអាន | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម | អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤-ឯកឧត្តម | ប៊ុន អ៊ុយ | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៦-ឯកឧត្តម | ឡាយ អ៊ីពិសិទ្ធិ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៧-ឯកឧត្តម | តេង សាវង្ស | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តម | កែប ជុតិមា | អភិបាល រាជធានីភ្នំពេញ | សមាជិក |
| ៩-ឯកឧត្តម | តេង ឈួន | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១០-លោក | ឡាយ ឫទ្ធី | នាយករង ទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ១១-ឯកឧត្តម | ឡេង ធនយុទ្ធា | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | លេខាអចិន្ត្រៃយ៍ |

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com